# ការវិភាគផ្អែកតាមបទពិសោធន៍ជាក់ស្តែង លើកត្តាកំណត់ការជ្រើសយកប្រភេទផ្សេងៗនៃ សកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ នៅតំបន់ជនបទក្នុងប្រទេសកម្ពុជា

**សេចក្តីផ្តើម**

នៅកម្ពុជា ប្រជាជនក្រីក្រ និងងាយរងគ្រោះជាងគេភាគច្រើន រស់នៅតំបន់ជនបទ និងមានជីវភាពពឹងផ្អែកលើវិស័យកសិកម្ម។ វិស័យកសិកម្មបានផ្លាស់ប្តូរយ៉ាងខ្លាំងក្នុង ១៥ឆ្នាំចុងក្រោយនេះ ប៉ុន្តែនៅតែមិនទាន់ស្រូបយកអស់នូវកម្លាំងពលកម្មក្នុងជនបទ ឬបង្កើតការងារឲ្យបានគ្រប់គ្រាន់ ហើយនាពេលបច្ចុប្បន្ន បានផ្តល់ការងារឲ្យមិនដល់ ៦០% នៃកម្លាំងពលកម្មនៅជនបទនោះទេ (CDRI 2013)។

បញ្ហាចម្បងដែលវិស័យកសិកម្មកំពុងប្រឈមមុខគឺ ផលិតភាពទាប សេវាផ្សព្វផ្សាយបច្ចេកទេសនៅមានកម្រិត ភាពទន់ខ្សោយនៃម្ចាស់ដីតូចៗក្នុងការចូលរួមក្នុងទីផ្សារ ផលិតកម្មពឹងលើធាតុអាកាស ការប្រែប្រួលអាកាសធាតុ និងកំណើនភាពគ្មានដីធ្លី។ ម៉្យាងការធ្វើកសិកម្មតាមរដូវកាល តម្រូវឲ្យកសិករស្វែងរកការងារក្រៅពីស្រែចំការផ្ទាល់ខ្លួន នៅពេលផុតរដូវដាំដុះ។ ដូច្នេះ ជីវភាពពឹងផ្អែកលើកសិកម្ម និងងាយរងគ្រោះស្រាប់នេះ វាកាន់តែមិននឹងន និងមានហានិភ័យច្រើនឡើង ក្នុងអំឡុងពេលមិនសូវមានការងារធ្វើ។

ដើម្បីកាត់បន្ថយភាពងាយរងគ្រោះក្នុងជីវភាព ហើយអាចទប់ទល់នឹងហានិភ័យក្នុងវិស័យកសិកម្ម ប្រជាជននៅជនបទជាច្រើន ជាពិសេសម្ចាស់ដីតូចៗ និងគ្រួសារគ្មានដីធ្លី ត្រូវចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ (ការងារមានប្រាក់កម្រៃ និង/ឬអាជីវកម្មផ្ទាល់ខ្លួន) ក្នុងវិស័យកសិកម្ម ឬវិស័យមិនមែនកសិកម្ម។ ប៉ុន្តែនៅតាមមូលដ្ឋាន ឱកាសការងារនៅមានតិច ព្រោះមិនទាន់មានសហគ្រាសខ្នាតតូច និងមធ្យម (SMEs) ដោយសារ តំបន់ជនបទមានកំណើនសេដ្ឋកិច្ចស្ទឹកយឺតយ៉ាវ។ ស្ថានភាពនេះ បានជំរុញឲ្យអ្នកនៅជនបទធ្វើចំណាកស្រុកទៅទីក្រុង និងក្រៅប្រទេស ដើម្បីរកការងារធ្វើ។ ម៉្យាងទៀត ចំណូលខ្ពស់បានពីការងារក្នុងវិស័យមិនមែនកសិកម្ម អាចទាក់ទាញគ្រួសារនៅជនបទ ឲ្យចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលពីការងារក្រៅពីកសិកម្ម។

ដោយសារបញ្ហាដូចខាងលើ ការសម្រេចចិត្តធ្វើការងារក្រៅពីមុខរបរស្រែចំការរបស់គ្រួសារនីមួយៗ អាចអាស្រ័យលើកត្តារុញច្រាន និងកត្តាអូសទាញមួយចំនួន ដូចជា ទីតាំង ជំនាញ និងទ្រព្យធន។ ជាទូទៅ គ្រួសារមានប្រាក់ចំណូលទាប តែងប្រឈមនឹងហានិភ័យកម្រិតខ្ពស់ជាង និងមានសមត្ថភាពតិច ក្នុងការទប់ទល់នឹងការប៉ះទង្គិចផ្សេងៗលើប្រាក់ចំណូល។ ដូច្នេះ ប្រភពចំណូលក្រៅពីមុខរបរស្រែចំការរបស់គ្រួសារក្រីក្ររំពឹងថានឹងមានច្រើនមុខ ជាងគ្រួសារធូរធារ។

សកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ បានក្លាយជាចំណុចសំខាន់បណ្តើរៗមួយនៃ យុទ្ធសាស្ត្រសម្រាប់ បំពេញបន្ថែម និងធ្វើពិពិធកម្មជីវភាពនៅជនបទ កែលំអសុខុមាលភាពនៅតាមជនបទ និងជាពិសេស កាត់បន្ថយហានិភ័យក្នុងវិស័យកសិកម្ម។ បច្ចុប្បន្ន ការធ្វើពិពិធកម្មប្រភពចំណូលរបស់គ្រួសារនៅតាមជនបទ កំពុងមានការយកចិត្តទុកដាក់ជាខ្លាំងពីអ្នកធ្វើគោលនយោបាយ។ គោលនយោបាយកាន់តែប្រសើរសម្រាប់បង្កើតការងារក្រៅពីមុខរបរស្រែចំការ និងកែលំអការគ្រប់គ្រងហានិភ័យក្នុងវិស័យកសិកម្ម តម្រូវឲ្យមានការយល់ដឹងកាន់តែប្រសើរពីកត្តារុញច្រាន-អូសទាញនានា និងឥទ្ធិពលរបស់វាទៅលើការសម្រេចចិត្តរបស់គ្រួសារ ដើម្បីចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។

ការសិក្សានេះមានគោលដៅពិនិត្យថា តើកត្តាណាខ្លះជួយកំណត់ជម្រើសនៃ ការចូលរួមក្នុងការងារក្រៅពីមុខរបរស្រែចំការនៅតាមជនបទកម្ពុជា។ អត្ថបទនេះមានការរៀបរាប់ដោយសង្ខេបពី ការប្រមូលទិន្នន័យ និងបច្ចេកទេសវិភាគដែលបានយកមកប្រើ និងលក្ខណៈសំខាន់ៗមួយចំនួននៃទិន្នន័យប្រមូលបាន។ បន្ទាប់មក មានការពិភាក្សាពីលទ្ធផលប៉ាន់ប្រមាណសម្រាប់ អថេរនីមួយៗដាច់ពីគ្នា និងសេចក្តីសន្និដ្ឋានខ្លីមួយផ្អែកលើលទ្ធផលរកឃើញសំខាន់ៗ។

## វិធីសាស្ត្រស្រាវជ្រាវ

***ការប្រមូលទិន្នន័យ***

ការសិក្សានេះ ប្រើប្រាស់ទិន្នន័យបានពីអង្កេតលើវិស័យកសិកម្មក្នុងឆ្នាំ២០១៥ សម្រាប់ការស្រាវជ្រាវមួយស្តីពី សកម្មភាពរកប្រាក់ចំណូល ក្រៅពីមុខរបរស្រែចំការក្នុងតំបន់ជនបទ (FAO 2015)។ អង្កេតនេះបានអនុវត្តឡើងក្នុង ៨ភូមិ នៅក្នុងខេត្តបាត់ដំបង កំពត ព្រៃវែង និងក្រចេះ ដែលតំណាងឲ្យតំបន់អេកូ-កសិកម្មផ្សេងៗ គឺតំបន់ទន្លេសាប តំបន់ឆ្នេរ តំបន់ទំនាបទន្លេមេគង្គ និងតំបន់ភ្នំ/ខ្ពង់រាប។ នៅក្នុងភូមិនីមួយៗ ក្រុមស្រាវជ្រាវបានជ្រើសរើសដោយចៃដន្យនូវ គ្រួសារចំនួន ៤០ គ្រួសារ (២០គ្រួសារ មានប័ណ្ណក្រីក្រ និង ២០គ្រួសារ មិនមាន

---

អត្ថបទនេះ រៀបចំដោយ ស៊ីម សុខចេង ប្រធានផ្នែកស្តីទី ថេង វុទ្ធី អតីតប្រធានផ្នែក ខៀវ ភិរម្យ អ្នកស្រាវជ្រាវ និង អៀ សុធី អ្នកស្រាវជ្រាវ ផ្នែកកសិកម្ម នៃវិទ្យាស្ថាន CDRI ។ សូមយោងឯកសារនេះថា៖ Sim Sokcheng, Theng Vuthy, Khiev Pirom and Ear Sothy. 2016. "An Empirical Analysis of Factors Determining Choices between Different Subcategories of Off-farm Activities in Rural Cambodia." *Cambodia Development Review* 20(1): 6-11.

ប័ណ្ណក្រីក្រ) សម្រាប់ធ្វើសម្ភាសន៍ ដូច្នេះសរុបទាំងអស់មាន ៣២០គ្រួសារកសិករសំណាក។

### *ការជ្រើសរើសអថេរ*

អថេរពឹងផ្អែក (dependent variable) គឺការចូលរួមក្នុងប្រភេទផ្សេងៗនៃ សកម្មភាពនៃការរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ។ ដើម្បីបង្ហាញពីលក្ខណៈច្រើនបែបយ៉ាង (ពោលគឺមានតម្លៃច្រើនជាងពីរ: polychotomous) អថេរនេះមានតម្លៃស្មើ 0 ប្រសិនបើសមាជិកគ្រួសារគ្មានចូលរួមសោះ ក្នុងសកម្មភាពធ្វើការងារក្រៅពីមុខរបរស្រែចំការ, មានតម្លៃ ១ សម្រាប់ការធ្វើការងារក្នុងវិស័យកសិកម្មតែមួយមុខ, មានតម្លៃ ២ សម្រាប់ការងារមិនមែនកសិកម្មតែមួយមុខ, មានតម្លៃ ៣ សម្រាប់ការងារក្នុងវិស័យកសិកម្ម និងមិនមែនកសិកម្មទាំងពីរមុខ, មានតម្លៃ ៤ សម្រាប់ការងារដែលជាអាជីវកម្មផ្ទាល់ខ្លួនតែមួយមុខ, មានតម្លៃ ៥ សម្រាប់ការងារដែលជាអាជីវកម្មផ្ទាល់ខ្លួន និងការងារមានប្រាក់កម្រៃទាំងពីរមុខ។ ការស្រាវជ្រាវពីមុនៗស្ដីពីការចូលរួមក្នុងការងារក្រៅពីមុខរបរស្រែចំការ បានគូសបញ្ជាក់ពី ឥទ្ធិពលនៃលក្ខណៈសំខាន់ៗរបស់គ្រួសារ ប្រជាសាស្ត្ររបស់គ្រួសារ លក្ខណៈនៃមូលធនមនុស្ស លក្ខណៈនៃស្រែចំការ ចំណូលមិនមែនបានមកពីពលកម្ម និងស្ថានភាពសេដ្ឋកិច្ចក្នុងមូលដ្ឋាន។ ដូច្នេះ ក្រុមស្រាវជ្រាវបានបញ្ចូលកត្តាទាំងនេះជា អថេរឯករាជ្យ (independent variables)។

### *ការធ្វើម៉ូដែលនៃការផ្គត់ផ្គង់កម្លាំងពលកម្មនៃសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ*

ការផ្គត់ផ្គង់កម្លាំងពលកម្មក្រៅពីមុខរបរស្រែចំការរបស់គ្រួសារនៅជនបទ អាចកំណត់ថាជា លទ្ធផលនៃឥទ្ធិពលអថេរឯករាជ្យផ្សេងៗ រួមមាន លក្ខណៈរបស់គ្រួសារ លក្ខណៈជាមូលធនមនុស្សនៃមេគ្រួសារ លក្ខណៈស្រែចំការ ចំណូលមិនមែនបានពីកម្លាំងពលកម្ម និងស្ថានភាពសេដ្ឋកិច្ចក្នុងមូលដ្ឋាន។ ផ្អែកតាម Haile Abraha, Peerlings and Gardebroek (2008) លទ្ធផលនេះអាចបញ្ជាក់ឡើងដោយ៖

$$\begin{cases} H^0 = f\left(P_q, P_x, \bar{A}, \bar{Y}, K, Z\right) & \text{if} \quad w > w^r \\ H^0 = 0 & \text{if} \quad w \leq w^r \end{cases}$$

នៅពេលដែលប្រាក់កម្រៃក្រៅពីមុខរបរធ្វើស្រែចំការ ($w$) វាច្រើនជាង ប្រាក់កម្រៃបម្រុង (reservation wage $w^r$) កសិករនឹងចូលរួមនៅក្នុងសកម្មភាពរកប្រាក់ចំណូល ក្រៅពីមុខរបរធ្វើស្រែចំការ។

### *ការធ្វើម៉ូដែលនៃការចូលរួមធ្វើការងារក្រៅពីមុខរបរស្រែចំការ (សូមមើលឯកសារជាភាសាអង់គ្លេស)*

### *ស្ថិតិបកស្រាយ*

ទាំងចំណូលបានពីស្រែចំការ និងចំណូល ក្រៅពីមុខរបរស្រែចំការ សុទ្ធតែសំខាន់សម្រាប់គ្រួសារភាគច្រើននៅជនបទ និងតំណាងឲ្យប្រមាណ ៩០% នៃប្រាក់ចំណូលសរុប (FAO 2015)។ មានសកម្មភាពក្រៅពីមុខរបរស្រែចំការ ៣ប្រភេទ ដែលគេកំណត់ថា ជាប្រភពចម្បងនៃចំណូលបានពីការងារក្រៅពីមុខរបរស្រែចំការ៖ ការងារក្នុងវិស័យកសិកម្ម ការងារមិនមែនកសិកម្ម និងអាជីវកម្មផ្ទាល់ខ្លួន។

ការងារនៅក្នុងវិស័យកសិកម្ម ជាទូទៅមាន សកម្មភាពគាំទ្រផ្សេងៗក្នុងវិស័យកសិកម្ម និងបណ្ដាសកម្មភាពក្រោយការប្រមូលផលដំណាំ[1] ការនេសាទខ្លះ ការដាំដុះស្រូវ ការដាំដំណាំហូបផលយូរឆ្នាំ ការយកផលព្រៃឈើ និងការកាប់ឈើ។ ការងារមិនមែនកសិកម្មភាគច្រើនជា ការងារក្នុងរោងចក្រកាត់ដេរ/សម្លៀកបំពាក់ រោងម៉ាស៊ីនកិនស្រូវ និងសំណង់។ អាជីវកម្មផ្ទាល់ខ្លួន ជាទូទៅមាន ការលក់ទំនិញរាយ និងការផ្ដល់សេវា ដូចជា ការដឹកជញ្ជូន

1 រួមបញ្ចូលទាំងសកម្មភាពបន្ទាប់បន្សំ ពាក់ព័ន្ធនឹងផលិតកម្មកសិកម្ម និងមិនមែនអនុវត្តសម្រាប់គោលដៅផលិតកម្ម (ឧ. ការរៀបចំដី ប្រមូលផល និងគ្រប់គ្រងសត្វល្អិតចង្រៃ) សកម្មភាពគាំទ្រផ្សេងៗសម្រាប់ផលិតកម្មសត្វចិញ្ចឹម និងការរៀបចំគ្រាប់ពូជសម្រាប់ដាំដុះបន្តទៀត។

តារាង១៖ ភាគរយនៃគ្រួសារមានសមាជិកចូលរួមក្នុងប្រភេទផ្សេងៗនៃសកម្មភាពក្រៅពីមុខរបរស្រែចំការ គិតតាមខេត្ត និងកម្រិតនៃភាពក្រីក្រ

| | បាត់ដំបង | កំពត | ក្រចេះ | ព្រៃវែង | ក្រីក្រ | មិនក្រីក្រ | សរុប |
|---|---|---|---|---|---|---|---|
| គ្មានសកម្មភាពក្រៅពីមុខរបរស្រែចំការ | 24.9 | 23.8 | 17.4 | 29.8 | 20.01 | 27.65 | 24.1 |
| មានការងារក្រៅពីមុខរបរស្រែចំការ | 75.1 | 76.3 | 82.6 | 70.2 | 79.99 | 72.35 | 75.9 |
| មានការងារក្នុងវិស័យកសិកម្មតែមួយមុខ | 17.5 | 10.0 | 36.3 | 6.3 | 25.33 | 10.59 | 17.5 |
| មានការងារមិនមែនកសិកម្មតែមួយមុខ | 22.5 | 30.0 | 12.5 | 36.3 | 21.33 | 28.82 | 25.3 |
| មានទាំងការងារក្នុងវិស័យកសិកម្ម និងមិនមែនកសិកម្ម | 7.5 | 5.0 | 11.3 | 10.0 | 13.33 | 4.12 | 8.4 |
| មានអាជីវម្មផ្ទាល់ខ្លួនតែមួយមុខ | 16.3 | 11.3 | 12.5 | 11.3 | 9.33 | 15.88 | 12.8 |
| មានទាំងអាជីវម្មផ្ទាល់ខ្លួននិងការងារយកប្រាក់កម្រៃ | 11.3 | 20.0 | 10.0 | 6.3 | 10.67 | 12.94 | 11.9 |

ប្រភព៖ អង្កេតគ្រួសារកសិករ ឆ្នាំ២០១៥

និងកន្លែងលំហែកំសាន្ត និងមានការផលិត និងលក់ផលិតផលសិប្បកម្មមួយចំនួនតូច។

ដូចមានបង្ហាញក្នុងតារាង១ ស្រាប់ ៧៦% នៃគ្រួសារទាំងអស់នៅក្នុងអង្កេត មានសមាជិកយ៉ាងតិច ១នាក់ ដែលបានចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។ អត្រានៃការចូលរួមនៅខេត្តក្រចេះ មានកម្រិតខ្ពស់ (៨២,៥%) ដោយឡែកនៅខេត្តព្រៃវែង វាមានកម្រិតទាបជាង (៧០,២%)។ ដំណាំដាំសម្រាប់លក់ (កៅស៊ូ ម្រេច ដំឡូងឈើ) ជាកត្តាចម្បងជំរុញការងារយកប្រាក់កម្រៃក្នុងវិស័យកសិកម្មនៅខេត្តក្រចេះ និងផ្ដល់នូវប្រភពចំណូលដល់ ៣៦,៣% នៃគ្រួសារក្នុងខេត្តនេះ។ ផ្ទុយទៅវិញ នៅខេត្តព្រៃវែង មានតែ ៦,៣% នៃគ្រួសារទាំងអស់ប៉ុណ្ណោះដែលធ្វើការក្រៅពីមុខរបរស្រែចំការ និងក្នុងវិស័យកសិកម្មតែមួយមុខ ហើយក្នុងវិស័យមិនមែនកសិកម្ម ការងារយកប្រាក់កម្រៃ មានចំណែកធំជាងគេ រហូតដល់ ៣៦,៣%។

ប្រមាណ ៣៤%[2] នៃគ្រួសារក្នុងអង្កេត បានចូលរួមក្នុងសកម្មភាពមិនមែនកសិកម្ម (តារាង១) ដែលជាប្រភេទចម្បងនៃការងារក្រៅពីមុខរបរស្រែចំការ ក្នុងការសិក្សានេះ។ ប្រភេទចម្បងបន្ទាប់នៃ សកម្មភាពក្រៅពីមុខរបរស្រែចំការ គឺគ្រួសារប្រមាណ ២៦% ធ្វើការងារក្នុងវិស័យកសិកម្ម ដែលជាទូទៅ មានស្រាប់នៅក្នុងភូមិ និងខេត្តរបស់គាត់ ហើយភាគច្រើនធ្វើស្រែចំការតាមរដូវកាល។ អ្នកធ្វើការក្នុងវិស័យមិនមែនកសិកម្ម ត្រូវទៅក្រៅភូមិដែលអាចនៅក្នុងខេត្តគាត់កំពុងរស់នៅ ឬខេត្តផ្សេង។

គ្រួសារក្រីក្រ ៨០% និង គ្រួសារមិនក្រីក្រ ៧២% បានរួមចំណែកក្នុងការងារក្រៅពីមុខរបរស្រែចំការ ដែលមានប្រភេទខុសៗគ្នាគួរឲ្យកត់សំគាល់។ សកម្មភាពកសិកម្ម ជាប្រភេទចម្បងនៃការងារក្រៅពីមុខរបរស្រែចំការ អនុវត្តដោយគ្រួសារក្រីក្រ (៣៩%) រីឯគ្រួសារមិនក្រីក្រ ផ្ដោតលើការងារមិនមែនកសិកម្ម និងអាជីវកម្មផ្ទាល់ខ្លួន។

## លទ្ធផលប៉ាន់ស្មាន

ផ្នែកនេះ ពិភាក្សាអំពីលទ្ធផលរកឃើញ (regression results) សម្រាប់ ការចូលរួមរបស់គ្រួសារក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ ដូចមានចុះក្នុងតារាង២ ។

### *លក្ខណៈរបស់គ្រួសារ*

ក្រុមស្រាវជ្រាវបានរកឃើញថា ភាពក្រីក្រមានផលប៉ះពាល់អវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើ ការងារក្នុងវិស័យកសិកម្ម។ លទ្ធផលនេះស្របតាម Shi, Heerink and Ou (2007) ដែលរកឃើញថា គ្រួសារក្រីក្រចង់ស្វែងរកប្រភពចំណូលផ្សេងៗទៀត។ ប៉ុន្តែ ម៉ូដែលអនុវត្តប្រើដោយក្រុមស្រាវជ្រាវបានបញ្ជាក់ថា ម្ចាស់ដីតូចៗដែលក្រីក្រ និងពលករគ្មានដីធ្លី គឺអាចរកបានការងារ (ទាំងការងារក្នុងវិស័យកសិកម្ម និងមិនមែនកសិកម្ម) តែនៅក្នុងតំបន់ជនបទប៉ុណ្ណោះ។ បញ្ហានេះអាចមកពី អត្រាសមាជិកគ្រួសារក្នុងបន្ទុកកម្រិតខ្ពស់ រហូតដល់ ០,៩ និងកង្វះខាតសមាជិកគ្រួសារសកម្មផ្នែកសេដ្ឋកិច្ចដើម្បីទៅស្វែងរកការងារនៅឯទីក្រុង ឬតំបន់ផ្សេងទៀត។[3]

គ្រួសារសម្បូរទ្រព្យសម្បត្តិ មានឱកាសច្រើន ក្នុងការចាប់ផ្តើមអាជីកម្ម ហើយក្លាយទៅជាអ្នកមានអាជីវកម្មផ្ទាល់ខ្លួន ឬក៏អាចរកបានការងារមិនមែនកសិកម្ម នៅខាងក្រៅមូលដ្ឋានរបស់ខ្លួន។ នៅក្នុងម៉ូដែលបានអនុវត្តប្រើនេះ អថេរ (dummy variable) សម្រាប់តំណាងឲ្យស្ថានភាពក្រីក្ររបស់គ្រួសារ (ក្រីក្រ=0, មិនក្រីក្រ=១) មិនមានសារៈសំខាន់ខាងស្ថិតិទេ សម្រាប់អាជីវកម្មផ្ទាល់ខ្លួន ឬការងារមិនមែនកសិកម្ម។ លក្ខណៈនេះបង្ហាញថា គ្រួសារក្រីក្រ និងមិនក្រីក្រ មិនទំនងជាមានអនុវត្ត អាជីវកម្មផ្ទាល់ខ្លួន ឬការងារយកប្រាក់កម្រៃមិនមែនកសិកម្មនោះទេ។

ទំហំគ្រួសារ ជះឥទ្ធិពលវិជ្ជមាន គួរឲ្យកត់សំគាល់ទៅលើប្រូបាប៊ីលីតេនៃ ការចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការសម្រាប់គ្រួសារដែលអាចចូលរួមក្នុងការងារវិស័យកសិកម្ម និងមិនមែនកសិកម្មទាំងពីរមុខ។ លទ្ធផលរកឃើញនេះ ស្របគ្នាជាមួយនឹង Leeuwen and Dekkers (2013) ដែលលើកថា នៅពេលចំនួនសមាជិកគ្រួសារកើនឡើង ប្រូបាប៊ីលីតេនៃការចូលរួមរបស់គ្រួសារនោះ នៅក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ ទាំងផ្នែកកសិកម្ម និងមិនមែនកសិកម្ម ក៏កើនឡើងដែរ។ គ្រួសារនៅជនបទ ត្រូវការប្រាក់ចំណូលបន្ថែម ដើម្បីបំពេញលើកង្វះប្រាក់ចំណូលបានពីស្រែចំការ។

ចំនួនឆ្នាំដែលគ្រួសារនីមួយៗ បានរស់នៅក្នុងភូមិរបស់ខ្លួនវាមានសារៈសំខាន់ផ្នែកស្ថិតិសម្រាប់ ការងារបម្រើខ្លួនឯង រីឯប្រភេទផ្សេងៗទៀតនៃសកម្មភាពក្រៅពីមុខរបរស្រែចំការ វាមានសញ្ញាអវិជ្ជមាន។ ដូច្នេះ កសិករមានការផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងសកម្មភាពកសិកម្ម ហើយចំណូលបានពីស្រែចំការសំខាន់ខ្លាំងណាស់សម្រាប់គាត់។ ចំណុចនេះបង្ហាញថា ចំណូលបានពីការងារក្រៅពីមុខរបរស្រែចំការ វាជួយបំពេញបន្ថែម ជាជាងប្រជែងគ្នាជាមួយនឹង ចំណូលរំពឹងថាបានពីស្រែចំការ។

### *លក្ខណៈប្រជាសាស្ត្រ និងមូលធនមនុស្ស*

អាយុមេគ្រួសារ ជះឥទ្ធិពលវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើការងារក្នុងវិស័យកសិកម្ម ហើយផលលើវដ្តនៃជីវិត (age-squared) ក៏ជះឥទ្ធិពលអវិជ្ជមានគួរឲ្យកត់សំគាល់ដែរ។ អាយុមានទំនាក់ទំនងវិជ្ជមានខ្លាំងជាមួយនឹង ប្រូបាប៊ីលីតេនៃការចូលរួមក្នុងការងារក្រៅពីមុខរបរស្រែចំការ។ ប៉ុន្តែ នៅពេលសមាជិកគ្រួសារកាន់តែចាស់អាយុ ប្រូបាប៊ីលីតេនៃការចូលរួមក្នុងការងារកសិកម្មយកប្រាក់កម្រៃ តែងថយចុះគួរឲ្យកត់សំគាល់។ ការស្រាវជ្រាវនេះ ផ្ដល់លទ្ធផលស្របគ្នាជាមួយ Haile Abraha, Peerlings and Gardebroek (2008) ដែលថា មេគ្រួសារវ័យក្មេងទំនងត្រូវការ និងអាចធ្វើបានច្រើនជាងនូវ ការងារក្រៅពីមុខរបរស្រែចំការ។

2 អ្នកមានការងារក្នុងវិស័យកសិកម្មតែមួយមុខ (២៥,៣%) បូកនឹង អ្នកមានទាំងការងារក្នុងវិស័យកសិកម្ម និងការងារមិនមែនកសិកម្ម (៨,៤%)។

3 អត្រាសមាជិកគ្រួសារក្នុងបន្ទុក (dependency ratio) របស់គ្រួសារ គឺជា ចំនួនសមាជិកគ្រួសារក្រោមអាយុ ១៥ឆ្នាំ និងលើ ៦៤ឆ្នាំ ចែកជាមួយនឹង ចំនួនសមាជិកធ្វើការងារនិងមានអាយុពី ១៥ឆ្នាំ ទៅ ៦៤ឆ្នាំ។

យេនឌ័រមេគ្រួសារ មិនមានផលប៉ះពាល់អ្វីគួរឲ្យកត់សម្គាល់ទេ ទៅលើការចូលរួមរបស់ម្ចាស់ដីតូចៗ និងអ្នកគ្មានដីធ្លី ក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។

កម្រិតអប់រំរបស់មេគ្រួសារ មិនមានផលប៉ះពាល់គួរឲ្យកត់សំគាល់ទេ ទៅលើ ការងារក្នុងវិស័យកសិកម្ម គឺស្របគ្នានឹងលទ្ធផលរកឃើញក្នុងការសិក្សាពីមុនៗដែលបង្ហាញពី ទំនាក់ទំនងអន់ខ្សោយរវាង ការអប់រំ នឹងការងារក្នុងវិស័យកសិកម្ម។ ការអប់រំជះឥទ្ធិពលវិជ្ជមានទៅលើការងារបម្រើខ្លួនឯង ទោះបីមិនមានសារៈសំខាន់ផ្នែកស្ថិតិក្តី ហើយជះឥទ្ធិពលវិជ្ជមានដោយមានសារៈសំខាន់ផ្នែកស្ថិតិ ទៅលើការងារបម្រើខ្លួនឯង និងការងារយកប្រាក់កម្រៃ នៅកម្រិត ១០%។ មេគ្រួសារមានការអប់រំខ្ពស់ តែងមានផលិតភាព និងសមត្ថភាពច្រើនជាង ក្នុងការធ្វើអាជីវកម្ម ឬរកបានការងារក្រៅពីមុខរបរស្រែចំការ។

ការបណ្តុះបណ្តាល ក៏ជះឥទ្ធិពលវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើ អាជីវកម្មផ្ទាល់ខ្លួនដែរ។ អ្នកដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ តែងមានសមត្ថភាពច្រើនជាងក្នុងការគ្រប់គ្រងអាជីវកម្ម ឬក្លាយជាអ្នកមានអាជីវកម្មផ្ទាល់ខ្លួន ប៉ុន្តែអ្នកដែលមិនមានជំនាញអ្វីពិសេស មិនទំនងអាចធ្វើដូច្នោះបានទេ។ គេតែងវាយការណ៍ថា កង្វះខាតជំនាញជាឧបសគ្គចម្បងមួយដល់ការធ្វើអាជីវកម្មផ្ទាល់ខ្លួន ដូច្នេះហើយនៅទីបំផុត គ្រួសារក៏ត្រូវប្រើជម្រើសចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ។

### *លក្ខណៈស្រែចំការ*

ទ្រព្យមានផលិតភាពរបស់គ្រួសារ ដូចជា ដីដាំដុះ/ទំហំដី ជាកត្តាបុព្វប្រធានយ៉ាងសំខាន់មួយទៀត នៃការចូលរួមរបស់គ្រួសារ ក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។ ទំហំស្រែចំការជះឥទ្ធិពលអវិជ្ជមាន គួរឲ្យកត់សំគាល់ទៅលើការងារមិនមែនកសិកម្ម និងអាជីវកម្មផ្ទាល់ខ្លួន (នៅកម្រិត ៥%) និងលើការងារយកប្រាក់កម្រៃ (នៅកម្រិត ១%)។

ដោយសារប្រាក់ចំណូលបានពីផលដំណាំ វាមិនគ្រប់គ្រាន់សម្រាប់ដោះស្រាយតម្រូវការប្រចាំថ្ងៃរបស់ខ្លួន ម្ចាស់ដីតូចៗ និងកសិករគ្មានដីធ្លី ទំនងទៅចូលរួមក្នុងការងារមិនមែនកសិកម្មតែមួយមុខ ឬក៏ក្នុងការងារក្នុងវិស័យកសិកម្មផង និងមិនមែនកសិកម្មផងទាំងពីរមុខ។ ប្រាក់ចំណូលរកបាននៅស្រែចំការអំពី ការចិញ្ចឹមសត្វ ការនេសាទ និងផលិតផលព្រៃឈើ ក៏ជះឥទ្ធិពលអវិជ្ជមានគួរឲ្យកត់សំគាល់ដែរទៅលើ ការចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។ លទ្ធផលរកឃើញនេះ ស្រដៀងគ្នានឹង ការសិក្សាពីមុនៗ ដែលបង្ហាញថា កំណើនប្រាក់ចំណូលបានពីសកម្មភាពធ្វើស្រែចំការ តែងកាត់បន្ថយការចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ។

### *លក្ខខណ្ឌសេដ្ឋកិច្ចក្នុងមូលដ្ឋាន*

កត្តាបុព្វប្រធាន និងកត្តាអូសទាញផ្នែកសេដ្ឋកិច្ច ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្តធ្វើការងារ ក្រៅពីមុខរបរស្រែចំការ របស់គ្រួសារនីមួយៗ។ ថ្លៃស្រូវ ដែលតំណាងឲ្យ ទីផ្សារផលិតផលកសិកម្មល្អឥតខ្ចោះ វាជះឥទ្ធិពលអវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើ ការងារមិនមែនកសិកម្ម នៅកម្រិត ៥%។ ចំណូលខ្ពស់បានពីផលស្រូវវស្សា ដោយសារ ថ្លៃស្រូវកើនឡើង វាធ្វើឲ្យថយចុះប្រូបាប៊ីលីតេនៃ ការចូលរួមរបស់គ្រួសារក្នុងការងារមិនមែនកសិកម្ម។ ចំណុចនេះបង្ហាញថា ថ្លៃនៅទីផ្សារដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ពី ការចូលរួមរបស់គ្រួសារនៅក្នុងសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ។

អថេរទីផ្សារហិរញ្ញវត្ថុ ដែលតំណាងដោយអត្រាការប្រាក់លើកម្ចី មិនមានជាប់ទាក់ទងអ្វីគួរឲ្យកត់សំគាល់ ជាមួយនឹង ប្រភេទណាមួយនៃសកម្មភាពរកប្រាក់ចំណូល ក្រៅពីមុខរបរស្រែចំការទាំងប្រាំប្រភេទនោះទេ។ ទោះបីជាមិនមានសារៈសំខាន់ផ្នែកស្ថិតិក្តី ក៏សញ្ញានៃការជះឥទ្ធិពលទៅលើអត្រាការប្រាក់កម្ចី វាមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ណាស់។ ក្រុមស្រាវជ្រាវបានរកឃើញឥទ្ធិពលអវិជ្ជមានលើអាជីវកម្មផ្ទាល់ខ្លួន ដែលបង្ហាញថា អត្រាការប្រាក់កាន់តែខ្ពស់ឡើង ធ្វើឲ្យថយចុះកាន់តែខ្លាំងនូវ ប្រូបាប៊ីលីតេរបស់គ្រួសារក្នុងការបង្កើតអាជីវកម្ម និងការក្លាយជាអ្នកមានអាជីវកម្មផ្ទាល់ខ្លួន។ ផ្ទុយទៅវិញ ក្រុមស្រាវជ្រាវបានរកឃើញទំនាក់ទំនងវិជ្ជមាន ជាមួយនឹង ការងារមិនមែនកសិកម្ម។

លទ្ធផលខាងលើអាចបញ្ជាក់ថា កំណើននៃអត្រាការប្រាក់កម្ចី អាចបង្កើនប្រូបាប៊ីលីតេនៃការចូលរួមក្នុងសកម្មភាពមិនមែនកសិកម្ម។ ដោយសារកសិករនៅជនបទភាគច្រើន ប្រើប្រាស់ឥណទានដើម្បីធ្វើវិនិយោគក្នុងផលិតកម្មកសិកម្ម ដូច្នេះកំណើនអត្រាការប្រាក់កម្ចី អាចកាត់បន្ថយផលចំណេញបានពីកសិកម្ម ហើយបង្ខំឲ្យកសិករទៅស្វែងរកប្រភពចំណូលផ្សេងទៀត អំពីការងារយកប្រាក់កម្រៃមិនមែនក្នុងវិស័យកសិកម្ម។ ដោយឡែក ប្រមាណ ៥៨% នៃគ្រួសារក្នុងអង្កេត បានប្រាប់ថា គាត់មិនអាចមានអាជីវកម្មផ្ទាល់ខ្លួន ឬចាប់ផ្តើមអាជីវកម្មបានទេ ពីព្រោះខ្វះដើមទុនសម្រាប់ធ្វើវិនិយោគ។

### *ទីតាំង និងកត្តានៅតាមភូមិ*

មេគុណប៉ាន់ស្មាននៃ អថេរតំណាងឲ្យទីតាំង (dummy variable) សម្រាប់ខេត្តក្រចេះ មានតួលេខវិជ្ជមាន និងមានសារៈសំខាន់ផ្នែកស្ថិតិ សម្រាប់ការមានការងារក្នុងវិស័យកសិកម្មតែមួយមុខ និងការងារមិនមែនកសិកម្មតែមួយមុខ។ ចំណុចនេះមានន័យថា កត្តានៅតាមភូមិ ដូចជា លទ្ធភាពចូលទីផ្សារ និងការអភិវឌ្ឍសេដ្ឋកិច្ច វារួមចំណែកធ្វើឲ្យ ការចូលរួមក្នុងការងារលើវិស័យកសិកម្មនៅខេត្តក្រចេះ មានប្រូបាប៊ីលីតេខ្ពស់គួរសម។ កត្តាទាំងនេះ ក៏មានសារៈសំខាន់គួរកត់សំគាល់ ប៉ុន្តែជះឥទ្ធិពលអវិជ្ជមាន ទៅលើការងារមិនមែនកសិកម្ម។ ភូមិទាំងពីរដែលគេបានធ្វើអង្កេតក្នុងខេត្តក្រចេះ ស្ថិតនៅដាច់ស្រយាលគួរសម ហើយមានដំណាំឧស្សាហកម្ម និងដំណាំដាំសម្រាប់លក់ជាច្រើន (កៅស៊ូ ដំឡូងឈើ ស្វាយចន្ទី ម្រេច និងពពួកសណ្តែក) នៅជុំវិញទីនោះ។ ទាំងអស់នេះបង្ហាញពីមូលហេតុដែលនៅខេត្តក្រចេះ មានគ្រួសារចូលរួមនៅក្នុងការងារធ្វើស្រែចំការ ច្រើនជាង ក្នុងការងារមិនមែនស្រែចំការ។

មេគុណ (dummy coefficient) សម្រាប់ខេត្តកំពតជះឥទ្ធិពលវិជ្ជមានគួរឲ្យកត់សំគាល់ទៅលើអាជីវកម្មផ្ទាល់ខ្លួន និង

ការងារយកប្រាក់កម្រៃ ហើយបង្ហាញពី ប្រូបាប៊ីលីតេខ្ពស់នៃការធ្វើអាជីវកម្មផ្ទាល់ខ្លួន និងការងារយកប្រាក់កម្រៃ។

## សេចក្តីសន្និដ្ឋាន

ការងារក្រៅពីមុខរបរស្រែចំការ និងការងារស្រែចំការ ជាប្រភពចំណូលចម្បងសម្រាប់គ្រួសារ។ ប្រមាណ ៧៦% នៃគ្រួសារក្នុងអង្កេត បានចូលរួមក្នុងទម្រង់ខ្លះនៃ សកម្មភាពរកចំណូលក្រៅពីមុខរបរស្រែចំការ។ ការងារមិនមែនកសិកម្ម ជាប្រភពចម្បងនៃចំណូលបានពីការងារក្រៅពីមុខរបរស្រែចំការ បន្ទាប់មកគឺ ការងារក្នុងវិស័យកសិកម្ម និងអាជីវកម្មផ្ទាល់ខ្លួន។

ការវិភាគផ្អែកលើបទពិសោធន៍ជាក់ស្តែង បង្ហាញថា គ្រួសារក្រីក្រ តែងចូលរួមក្នុងការងារកសិកម្ម ឬការងារមិនមែនកសិកម្មនៅជនបទ ក្នុងចំនួនច្រើនជាង គ្រួសារមិនក្រីក្រ។ ស្ថានភាពនេះប្រហែលដោយសារ គ្រួសារក្រីក្រមានតិចជាងនូវ កម្លាំងពលកម្មកំពុងធ្វើសកម្មភាពសេដ្ឋកិច្ច ដូចអាចមើលឃើញតាម អត្រាសមាជិកគ្រួសារក្នុងបន្ទុកកម្រិតខ្ពស់ ដូច្នេះហើយក៏មិនអាចទៅធ្វើសកម្មភាពក្រៅពីមុខរបរស្រែចំការប្រភេទផ្សេងទៀត ជាពិសេសការងារនៅក្រៅភូមិ។

គ្រួសារមិនក្រីក្រ តែងចូលរួមក្នុងប្រភេទផ្សេងៗនៃការងារក្រៅពីស្រែចំការផ្ទាល់ខ្លួន ឬអាជីវកម្មផ្ទាល់ខ្លួន គួបផ្សំនឹង ការងារក្រៅពីមុខរបរស្រែចំការ និងយកប្រាក់កម្រៃ។ សញ្ញាអវិជ្ជមានសម្រាប់ទំនាក់ទំនងរវាង រយៈពេលដែលគ្រួសារមួយរស់នៅក្នុងភូមិនោះជាមួយនឹង ការងារក្រៅពីមុខរបរស្រែចំការ បង្ហាញអំពីការផ្សារភ្ជាប់យ៉ាងខ្លាំងនៃគ្រួសារនៅជនបទ ទៅនឹងសកម្មភាពកសិកម្ម។ ប្រសិនបើ ចំណូលបានពីស្រែចំការតែមួយមុខ វាអាចផ្គត់ផ្គង់ជីវភាពបានគ្រប់គ្រាន់នោះ គ្រួសារនៅជនបទទំនងជាផ្តោតទៅលើការងារស្រែចំការ ជាជាង សកម្មភាពក្រៅពីមុខរបរស្រែចំការ។ ពួកគេចង់រស់នៅក្នុងភូមិរបស់ខ្លួន ជាជាងការធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើ។

ក្នុងចំណោមលក្ខណៈប្រជាសាស្ត្ររបស់គ្រួសារ និងលក្ខណៈមូលធនមនុស្ស អាយុ និងការបណ្តុះបណ្តាលរបស់មេគ្រួសារ ជះឥទ្ធិពលយ៉ាងសំខាន់ផ្នែកស្ថិតិ ទៅលើ ការចូលរួមក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ។ ការបណ្តុះបណ្តាល ក៏ដើរតួនាទីសំខាន់ដែរ ក្នុងការចាប់ផ្តើមអាជីវកម្ម ឬធ្វើអាជីវកម្មផ្ទាល់ខ្លួន និងក្នុងការរកបានការងារក្រៅពីមុខរបរស្រែចំការ និងយកប្រាក់កម្រៃ។ ទ្រព្យសម្បត្តិគ្រួសារ ជាពិសេស ទំហំដីដាំដុះ ជាកត្តាសំខាន់មួយដែលកំណត់ការសម្រេចចិត្តរបស់គ្រួសារ ក្នុងការធ្វើការងារក្រៅពីមុខរបរស្រែចំការ។ ម្ចាស់ដីតូចៗ និងគ្រួសារគ្មានដីធ្លី ទំនងចូលរួមច្រើនជាងក្នុងការងារមិនមែនស្រែចំការ។

សរុបមក លក្ខខណ្ឌសេដ្ឋកិច្ចក្នុងមូលដ្ឋាន ដូចជា លទ្ធភាពចូលទីផ្សារ ការអភិវឌ្ឍសេដ្ឋកិច្ច និងទីតាំងភូមិសាស្ត្រ ក៏ជះឥទ្ធិពល (កត្តាអូសទាញ) ទៅលើការសម្រេចចិត្តរបស់គ្រួសារក្នុងការចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូល ក្រៅពីមុខរបរស្រែចំការ។ ចំណុចសំខាន់បំផុត ក្រុមស្រាវជ្រាវបានរកឃើញនូវទំនាក់ទំនងអវិជ្ជមានយ៉ាងខ្លាំង រវាង ទីផ្សារផលិតផលកសិកម្មជាមួយនឹង ការងារមិនមែនកសិកម្ម។ កំណើនថ្លៃស្រូវ ជួយបង្កើនចំណូលបានពីផលិតកម្មស្រូវ និងកាត់បន្ថយការចូលរួមរបស់គ្រួសារក្នុងការងារមិនមែនកសិកម្ម។ ការងារកសិកម្មតែងមានច្រើនជាង នៅតាមតំបន់មានការដាំដុះដំណាំដាំសម្រាប់លក់ និងដំណាំឧស្សាហកម្ម ដូចជានៅខេត្តក្រចេះ ជាដើម។ ស្រដៀងគ្នានេះដែរ ទីតាំងមានការប្រមូលផ្តុំសកម្មភាពសេដ្ឋកិច្ចច្រើន ដូចជានៅខេត្តកំពត ជាដើម តែងមានផ្តល់ច្រើនជាងនូវ ឱកាសសម្រាប់ធ្វើអាជីវកម្មផ្ទាល់ខ្លួន និងឱកាសធ្វើអាជីវកម្មផ្សេងៗ។

## ឯកសារយោង


Chang, Hung-Hao, and Ashok Mishra. 2008. "Impact of Off-farm Labor Supply on Food Expenditures of the Farm Household." Food Policy 33(6):657-664. http://dx.doi.org/10.1016/j.foodpol.2008.02.002.

CDRI (Cambodia Development Research Institute). 2013. Cambodia's Development Dynamics: Past Performance and Emerging Priorities. Phnom Penh: CDRI.

FAO (Food and Agricutural Organization). 2015. "Study on Off-farm Income Generation Activities in Cambodia." Unpublished.

Haile Abraha, N., J.H.M. Peerlings and C. Gardebroek. 2008. "Off-farm Labor Supply and the Role of Rainfall: A Case Study in Tigray, Northern Ethiopia." Proceedings of the 6th International Conference on the Ethiopian Economy, Bahir Dar University, Ethiopia, 3-5 July.

van Leeuwen, Eveline, and Jasper Dekkers. 2013. "Determinants of Off-farm Income and its Local Patterns: A Spatial Microsimulation of Dutch Farmers." Journal of Rural Studies 31:55-66. http://dx.doi.org/10.1016/j.jrurstud.2013.02.002.

Shi, Xiaoping, Nico Heerink and Futian Qu. 2007. "Choices between Different Off-farm Employment Sub-categories: An Empirical Analysis for Jiangxi Province, China." China Economic Review 18(4):438-455. http://dx.doi.org/10.1016/j.chieco.2006.08.001.


---

*តពីទំព័រ ៤* **ការចុះបញ្ជីដីធ្លី...**


Markus, G., and C. Udry. 2008. "The Profits of Power: Land Rights and Agricultural Investment in Ghana." *Journal of Political Economy* 116(6): 981-1022.

Markussen, T. 2008. "Property Rights, Productivity and Common Property Resources: Insights from Rural Cambodia." *World Development* 36(11): 2277-2296.

MLMUPC. 2013. *Report on Land Administration for Dissemination under Land Administration Sub-Sector Program.* Phnom Penh: Ministry of Land Management Urban Planning and Construction in Cambodia.

Sar, S. 2010. "Land Reform in Cambodia." Paper presented at the International Federation of Surveyors Congress, Kuala Lumpur, 16-21 June. Unpublished document.

de Soto, Hernando. 1986. "The Mystery of Capital." *Journal of Commonwealth Law and Legal Education* 2(2): 73-88.

de Soto, Hernando. 2000. *The Mystery of Capital: Why Capitalism Triumphs in the West and Fails Everywhere Else.* New York: Basic Books.

Sry B. 2013. "On Effectiveness of Systematic Land Tittling in Rural Cambodia." Master's thesis, University of Tsukuba, Japan.

Thomson, A. 2010. *Gender Equality in Systematic Land Registration.* Phnom Penh: Canadian International Development Agency.

Torhonen, P.M. 2001. "Developing Land Administration in Cambodia." *Computers, Environment and Urban Systems* 25(4-5): 407-428.

តារាង ២៖ លទ្ធផល multinomial probit regression សម្រាប់ការចូលរួមរបស់គ្រួសារក្នុងប្រភេទផ្សេងៗ នៃសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ

| | អថេរពឹងអាស្រ័យ (dependent variable): ការចូលរួមរបស់គ្រួសារក្នុងសកម្មភាពក្រៅពីមុខរបរស្រែចំការ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ការងារក្នុងវិស័យកសិកម្ម | | ការងារមិនមែនកសិកម្ម | | ទាំងការងារកសិកម្ម និងមិនមែនកសិកម្ម | | អាជីវកម្មផ្ទាល់ខ្លួន | | អាជីវកម្មផ្ទាល់ខ្លួន និងការងារយកប្រាក់កម្រៃ | |
| | មេគុណ | z | មេគុណ. | z | មេគុណ | z | មេគុណ. | z | មេគុណ. | z |
| ***លក្ខណៈរបស់គ្រួសារ*** | | | | | | | | | | |
| គ្រួសារ_ក្រីក្រ | -1.0450*** | -3.41 | 0.1393 | 0.5 | -0.8985*** | -2.53 | 0.0444 | 0.15 | -0.4783 | -1.44 |
| គ្រួសារ_ទំហំ | 0.0475 | 0.53 | 0.1032 | 1.27 | 0.3486*** | 3.54 | -0.1389 | -1.53 | 0.0909 | 1.04 |
| គ្រួសារ_ឆ្នាំ_ភូមិ | -0.0130 | -0.89 | -0.0171 | -1.31 | -0.0057 | -0.36 | -0.0333* | -2.26 | -0.0044 | -0.3 |
| ***លក្ខណៈប្រជាសាស្ត្រ និងមូលធនមនុស្ស*** | | | | | | | | | | |
| មេគ្រួសារ_ភេទ | 0.3797 | 1.04 | 0.2619 | 0.8 | 0.6004 | 1.45 | -0.0008 | 0 | 0.5000 | 1.24 |
| មេគ្រួសារ_អាយុ | 0.1557*** | 2.51 | 0.0655 | 1.14 | 0.0808 | 1.08 | 0.0830 | 1.44 | 0.2174*** | 2.84 |
| មេគ្រួសារ_អាយុ2 | -0.0018*** | -2.97 | -0.0008 | -1.34 | -0.0009 | -1.25 | -0.0009 | -1.54 | -0.0019*** | -2.76 |
| មេគ្រួសារ_ការអប់រំ | -0.0765 | -1.56 | -0.0225 | -0.54 | -0.1169** | -2.09 | 0.0059 | 0.13 | 0.0793* | 1.61 |
| មេគ្រួសារ_ការបណ្តុះបណ្តាលវិជ្ជាជីវៈ | 0.2053 | 0.48 | 0.0715 | 0.21 | -0.5505 | -0.88 | 0.7693** | 2.14 | 0.8273*** | 2.09 |
| ***លក្ខណៈកសិដ្ឋាន*** | | | | | | | | | | |
| ការដាំដុះ_ដី | 0.0263 | 0.32 | -0.2311** | -2.03 | -0.3229* | -1.79 | 0.0121 | 0.15 | -0.4687*** | -3 |
| ចំណូលសរុប_សត្វចិញ្ចឹម | 0.0002 | 0.32 | 0.0002 | 0.28 | 0.0005 | 0.59 | 0.0009 | 1.18 | 0.0009 | 1.39 |
| ចំណូលសរុប_នេសាទ | -0.0001 | -0.09 | -0.0025* | -1.68 | -0.0014 | -1.03 | -0.0011 | -0.37 | -0.0007 | -0.38 |
| ចំណូលសរុប_ព្រៃឈើ | -0.0052* | -1.66 | -0.0021 | -0.75 | -0.0052* | -1.8 | -0.0081*** | -2.62 | -0.0044 | -1.43 |
| ***ស្ថានភាពសេដ្ឋកិច្ចនៅមូលដ្ឋាន*** | | | | | | | | | | |
| ថ្លៃ_ស្រូវវស្សា | -0.0010 | -0.2 | -0.0083** | -1.93 | -0.0067 | -1.35 | -0.0035 | -0.72 | -0.0121** | -2.43 |
| អត្រា_កម្ចី | -0.0812 | -0.84 | 0.0514 | 1.06 | -0.1637 | -1.4 | -0.0734 | -0.71 | -0.0831 | -0.62 |
| បាត់ដំបង | 0.6252 | 1.46 | -0.1410 | -0.4 | -0.2294 | -0.5 | 0.3949 | 0.97 | 0.5329 | 1.19 |
| កំពត | 0.3139 | 0.43 | 0.7050 | 1.33 | 0.1126 | 0.17 | 0.2123 | 0.34 | 2.1248*** | 3.46 |
| ក្រចេះ | 1.4475*** | 2.7 | -1.0022** | -1.93 | -0.3322 | -0.58 | 0.4890 | 0.84 | 0.0933 | 0.15 |
| ថេរ (constant) | -1.6130 | -0.37 | 6.7087 | 1.74 | 4.2204 | 0.85 | 3.0651 | 0.72 | 4.3444 | 0.9 |
| ចំនួនករណីបានពិនិត្យសង្កេត | 320 | | | | | | | | | |
| Wald chi2(85) | 238.0 | | | | | | | | | |
| Log pseudolikelihood | -452.1 | | | | | | | | | |

កំណត់សំគាល់: មានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិត *10%, **5% និង ***1%

ចេញផ្សាយថ្មីៗ

# ការប្រែប្រួលអាកាសធាតុ និង អភិបាលកិច្ចធនធានទឹកនៅកម្ពុជា

## បញ្ហាប្រឈម និងការប្រមើលពីសន្តិសុខទឹក និងការប្រែប្រួលអាកាសធាតុ ក្នុងអាងស្ទឹងមួយចំនួននៅកម្ពុជា




គម្រោងសិក្សាផ្តោតលើដែនរងទឹកភ្លៀងបី នៅជុំវិញបឹងទន្លេសាប មានស្ទឹងជ្រៃបាក់ក្នុងខេត្តកំពង់ឆ្នាំង ស្ទឹងជីនិតក្នុងខេត្តកំពង់ធំ និងស្ទឹងពោធិ៍សាត់ក្នុងខេត្តពោធិ៍សាត់។ លទ្ធផលស្រាវជ្រាវចម្បងៗមានជាអាទិ៍ (១) ការយល់ដឹងកាន់តែប្រសើរ ក្នុងចំណោមអ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកស្រាវជ្រាវ សិស្ស និងនិស្សិត អំពីផលពាក់ព័ន្ធដល់ជីវភាពរស់នៅនៃការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងធារាសាស្ត្រ បណ្តាលមកពី ការប្រែប្រួលអាកាសធាតុ និងប្រព័ន្ធមនុស្សនៅអាងទន្លេសាប និង (២) វិធីប្រសើរឡើងដើម្បីដាក់បញ្ចូលចំណេះដឹងមូលដ្ឋាន និងភស្តុតាងជាក់ស្តែងផ្អែកវិទ្យាសាស្ត្រ ទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងការធ្វើផែនការនៅកម្ពុជា។

ការវាយតម្លៃគ្រប់ជ្រុងជ្រោយពី បញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ចទឹក ការប្រែប្រួលអាកាសធាតុ និងសមត្ថភាពបន្សាំ ក្នុងបីខេត្ត បង្ហាញថា ការផ្លាស់ប្តូរផ្សេងៗនៃអាកាសធាតុកំពុងប៉ះពាល់ដល់ជីវភាពរស់នៅក្នុងសហគមន៍មូលដ្ឋាន ហើយផលប៉ះពាល់នេះប្រែប្រួលខុសៗគ្នាទៅតាមតំបន់។ ការរំកិលពេលចាប់ផ្តើមធ្លាក់ភ្លៀងនៅរដូវវស្សា មានផលពាក់ព័ន្ធយ៉ាងច្បាស់ទាំងទៅលើការធ្វើស្រែប្រាំង និងស្រែវស្សា។ ការសិក្សានេះក៏គូសរំលេចផងដែរនូវបញ្ហាដែលប៉ះពាល់ខ្លាំងបំផុតដល់សហគមន៍មូលដ្ឋាន ជាពិសេស កំណើនប្រេកង់ទឹកជំនន់ និងព្យុះភ្លៀងមានរន្ទះ ដែលពួកគេយល់ថាជាភាពងាយរងគ្រោះមួយដែរទៅនឹងការប្រែប្រួលអាកាសធាតុ។

ការធ្វើផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវមានការសម្រេចចិត្តដោយមានកិច្ចសហការគ្នា ព័ត៌មានគ្រប់គ្រាន់ និងក្របខ័ណ្ឌមួយសម្រាប់បញ្ជ្រាបបញ្ហាធន់នឹងអាកាសធាតុ ទៅក្នុងការធ្វើផែនការអភិវឌ្ឍន៍។ CDRI និងដៃគូសហការនានា មានការត្រេកអរដោយបានចូលរួមជួយកែលំអការធ្វើផែនការផ្អែកលើវិទ្យាសាស្ត្រ សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានទឹក នៅអាងទន្លេសាប។ ចំណេះដឹងទទួលបានពីគម្រោងនេះនឹងជួយលើកកម្ពស់ ការយល់ដឹងរបស់អ្នកធ្វើការសម្រេចចិត្តនៅកម្រិតមូលដ្ឋាន និងកម្រិតជាតិ អំពី (១) បែបបទដែលការប្រែប្រួលនៃអាកាសធាតុ និងប្រព័ន្ធមនុស្ស ជះឥទ្ធិពលទៅលើបរិមាណទឹក និងសន្តិសុខទឹក (២) ផលពាក់ព័ន្ធនៃការប្រែប្រួលក្នុងបរិមាណទឹកដែលមាន ទៅដល់ជីវភាពរស់នៅក្នុងតំបន់ដែនរងទឹកភ្លៀងបានចុះសិក្សា និង (៣) បែបបទដែលការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹក អាចជួយបង្កើនសមត្ថភាពបន្សាំ និងសម្រេចបានសន្តិសុខទឹក។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh។
ឯកសារបោះពុម្ពផ្សាយអាចរកបាននៅវិទ្យាស្ថាន CDRI និងនៅហាងលក់សៀវភៅ ម៉ូនូរ៉ម៉ែន។